សុន្ទរកថារបស់**លោក តាខ៉ាមូរ៉ា ហ៊ីរ៉ូស៊ី** ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយសម្រាប់គម្រោង ទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២៣ មិនា ២០១២

**សូមគោរព លោក ហឿង ថុល ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជើងព្រៃ-បាធាយ!**
**សូមគោរព លោក យឹម ចន្ថា ប្រធានមន្ទីរពេទ្យបង្អែកជើងព្រៃ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំ នសេចក្ដីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយជាមួយស្រុកប្រតិបត្តិជើងព្រៃ-បាធាយសម្រាប់ជំនួយទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

ជំនួយដែលមានទឹកប្រាក់សរុបចំនួន **៩២,២៩០ដុល្លាអាមេរិក** នេះត្រូវបានផ្ដល់ជូនដើម្បីបំពាក់សម្ភារៈបរិក្ខារពេទ្យក្នុងមន្ទីរពេទ្យបង្អែកជើងព្រៃក្នុងខេត្តកំពង់ចាម។

តាមរយៈការស្នើសុំរបស់ស្រុកប្រតិបត្តិជើងព្រៃ-បាធាយ និងការអង្កេតដល់ទីកន្លែងដែលធ្វើឡើងដោយបុគ្គលិកស្ថានទូត យើងទទួលស្គាល់នូវតម្រូវការបន្ទាន់នៃសម្ភារៈបរិក្ខារពេទ្យសម្រាប់បន្ទប់វះកាត់ក្នុងមន្ទីរពេទ្យបង្អែកជើងព្រៃដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវសេវាសង្គ្រោះបន្ទាន់ និងវះកាត់។

កិច្ចសហប្រតិបត្តិការជាអាទិភាពមួយក្នុងចំណោមកិច្ចសហប្រតិបត្តិការជាអាទិភាពនានារបស់រដ្ឋាភិបាលជប៉ុនជាមួយព្រះរាជាណាចក្រកម្ពុជាគឺការគាំទ្រវិស័យសុខាភិបាល។ ដោយអនុលោមទៅតាមផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ជាតិ យើងបាននិងកំពុងបន្តឧបត្ថម្ភគាំទ្រដល់មន្ទីរពេទ្យបង្អែកនៅតាមបណ្ដាខេត្តនានាដើម្បីបង្កើនសេវាកម្មថែទាំសុខភាពសម្រាប់ប្រជាជននៅតាមតំបន់។

តាមរយៈគម្រោងនេះ អ្នកជំងឺនៅក្នុងមន្ទីរពេទ្យបង្អែកជើងព្រៃនឹងទទួលបានសេវាវះកាត់កាន់តែប្រសើរឡើង។ ជាងនេះទៅទៀត អង្គការក្រៅរដ្ឋាភិបាលជប៉ុន "Japan Hearts"កំពុងជួយដល់ការកសាងសមត្ថភាពផ្នែកវះកាត់នៅក្នុងមន្ទីរពេទ្យ ដូច្នេះយើងរំពឹងថានឹងទទួលបានប្រសិទ្ធភាពកាន់តែប្រសើរឡើង។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងនេះនឹងរួមចំណែកដល់ការលើកស្ទួយសុខុមាលភាពរបស់ប្រជាជន ២០០,០០០នាក់នៅក្នុងស្រុកជើងព្រៃ និងស្រុកបាធាយនៃខេត្តកំពង់ចាម។ ខ្ញុំក៏សង្ឃឹមផងដែរថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនង មិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!